ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
រដ្ឋបាលជលផល

លេខ: ......៨៥៤......... ជផ

# សេចក្តីសម្រេច
# ស្តីពី
# គោលការណ៍ណែនាំបច្ចេកទេសសម្រាប់កម្មវិធីជាតិ តាមដាននិងត្រួតពិនិត្យសំណល់ឱសថវារីសត្វនិងសារធាតុគីមីក្នុងវារីវប្បកម្ម

## ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា
## ប្រធានរដ្ឋបាលជលផល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២២/០០៦ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩១២/០០៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញារ៉ូប៊ីដាម ស្តីពីនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុនចំពោះសារធាតុគីមី និងថ្នាំកសិកម្មគ្រោះថ្នាក់ក្នុងពាណិជ្ជកម្មអន្តរជាតិ

- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ
- បានឃើញអនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីអនាម័យនៃម្ហូបអាហារសំរាប់មនុស្ស
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ៣៨៦ ប្រក.កសក.ប ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពរបស់រដ្ឋបាលជលផល
- បានឃើញប្រកាសលេខ៦៨១ ប្រក.កសក.ប ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ការិយាល័យនិងមន្ទីរពិសោធន៍ចំណុះនាយកដ្ឋាន និងវិទ្យាស្ថានក្រោមឱវាទរដ្ឋបាលជលផល
- បានឃើញប្រកាសលេខ ១១៣ ប្រក.កសក.ប ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ការិយាល័យចំណុះមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍន៍វារីវប្បកម្មសមុទ្រ
- យោងតាមការចាំបាច់របស់រដ្ឋបាលជលផល

## សម្រេច

**ប្រការ ១ .-**

សេចក្តីសម្រេចនេះ កំណត់អំពីគោលការណ៍ណែនាំបច្ចេកទេសសម្រាប់កម្មវិធីជាតិតាមដាននិងត្រួតពិនិត្យសំណល់ឱសថវារីសត្វនិងសារធាតុគីមីក្នុងវារីវប្បកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីកាត់បន្ថយភាពស៊ាំនឹងឱសថប្រឆាំងមេរោគ(AMR) ដោយផ្អែកតាមអភិក្រមសុខភាពតែមួយ(One Health) និងឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវផ្នែកសុវត្ថិភាពម្ហូបអាហារ ក្នុងការចូលរួមការពារសុខភាពសាធារណៈ និងជំរុញការនាំចេញផល ផលិតផលជលផលកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ ស្របតាមគោលការណ៍ណែនាំបច្ចេកទេសនិងស្តង់ដារពាក់ព័ន្ធរបស់គណៈកម្មាធិការកូដិចអន្តរជាតិ (Codex Alimentarius) និងក្រមសុខភាពវារីសត្វរបស់អង្គការសុខភាពសត្វពិភពលោក(WOAH Aquatic Animal Health Code)។

**ប្រការ ២ .-**

សេចក្តីសម្រេចនេះ មានវិសាលភាពអនុវត្តចំពោះកសិដ្ឋានវារីវប្បកម្មនិងកន្លែងកែច្នៃផល ផលិតផលជលផលក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣ .-**

គោលការណ៍ណែនាំបច្ចេកទេសសម្រាប់កម្មវិធីជាតិតាមដាននិងត្រួតពិនិត្យសំណល់ឱសថវារីសត្វនិងសារធាតុគីមីក្នុងវារីវប្បកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា មានភ្ជាប់ជាឧបសម្ព័ន្ធ នៃសេចក្តីសម្រេចនេះ។

**ប្រការ ៤ .-**

សេចក្តីសម្រេច ឬបទបញ្ញាទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥ .-**

ប្រធាននាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលនិងនីតិកម្ម ប្រធាននាយកដ្ឋានបច្ចេកវិទ្យាកែច្នៃនិងគុណភាព គ្រប់អង្គភាពក្រោមឱវាទរដ្ឋបាលជលផល ត្រូវសហការផ្សព្វផ្សាយនិងអនុវត្តគោលការណ៍ណែនាំបច្ចេកទេសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ១៣កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០២៤

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

**ពុំ សុធា**

**ចម្លងជូន ៖**

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៥
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ

ភ្ជាប់សេចក្តីសម្រេចលេខៈ ៩៥៤ សជ ............ ចុះថ្ងៃទី២៦ ខែ មីនា ឆ្នាំ២០២៤

# គោលការណ៍ណែនាំបច្ចេកទេស
# សម្រាប់ការអនុវត្តកម្មវិធីជាតិតាមដាន និងត្រួតពិនិត្យ
# សំណល់ឱសថវារីសត្វ និងសារធាតុគីមីក្នុងផលវារីវប្បកម្ម
# ក្នុងព្រះរាជាណាចក្រកម្ពុជា

# ឧបសម្ព័ន្ធ

ភ្ជាប់សេចក្ដីសម្រេចលេខៈ ៩៥៤ ជផ ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ២០២៤

# គោលការណ៍ណែនាំបច្ចេកទេស
# សម្រាប់ការអនុវត្តកម្មវិធីជាតិតាមដាន និងត្រួតពិនិត្យ
# សំណល់ឱសថវារីសត្វ និងសារធាតុគីមីក្នុងផលវារីវប្បកម្ម
# ក្នុងព្រះរាជាណាចក្រកម្ពុជា

# មាតិកា


ទំព័រ

**ពាក្យបំព្រួញ** ........ ០៣

**១. សេចក្តីផ្តើម** ........ ០៤

**២. គោលបំណង** ........ ០៥

**៣. វិសាលភាព** ........ ០៥

**៤. ការរៀបចំទូទៅ** ........ ០៥

៤.១ ការបង្កើតគណកម្មាធិការគ្រប់គ្រង NRMP ........ ០៥

៤.២ ការបង្កើតក្រុមការងារប្រតិបត្តិ NRMP ........ ០៦

៤.៣ ការជ្រើសរើសនិងកំណត់យកមន្ទីរពិសោធន៍ ........ ០៧

**៥. ស្តង់ដារប្រតិបត្តិ** ( SOP ) ........ ០៨

៥.១ ការរៀបចំផែនការប្រចាំឆ្នាំ ........ ០៨

៥.២ ការរៀបចំផែនការសកម្មភាពលម្អិត ........ ១១

៥.៣ ការប្រមូល និងវិភាគសំណាក ........ ១១

៥.៤ ការរៀបចំនិងបញ្ជូនសំណាក និងការទទួលលទ្ធផលវិភាគពីមន្ទីរពិសោធន៍ ........ ១៦

៥.៥ ការត្រួតពិនិត្យសារឡើងវិញជាបន្ទាន់ចំពោះភាពមិនអនុលោម ........ ១៨

៥.៦ ការប្រមូលសំណាកដើម្បីអង្កេតតាមដាន និងវាយតម្លៃសារជាថ្មី ........ ២០

៥.៧ ការរៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ........ ២២

៥.៨ ការតាមដាននិងវាយតម្លៃប្រចាំឆ្នាំ ........ ២២

**៦. សារធាតុគីមីដែលតម្រូវវិភាគក្នុងផលវារីវប្បកម្ម** ........ ២៣

**៧. ឧបសម្ព័ន្ធ** ........ ២៦

ឧបសម្ព័ន្ធ ១. តារាងទិន្នន័យសម្រាប់ផែនការប្រចាំឆ្នាំជាមួយចំនួនសំណាក និង ប៉ារ៉ាម៉ែត្រ (ទម្រង់ទី១) ........ ២៦

ឧបសម្ព័ន្ធ ២. តារាងទិន្នន័យលទ្ធផលវិភាគប្រៀបនឹងផែនការប្រចាំឆ្នាំ (ទម្រង់ទី២) ........ ៣១

ឧបសម្ព័ន្ធ ៣. ផែនការ និងរបាយការណ៍ប្រមូលសំណាក (ទម្រង់ទី៣) ........ ៣៦

ឧបសម្ព័ន្ធ ៤. ការបញ្ជូនសំណាកនិងស្នើរសុំវិភាគ (ទម្រង់ទី៤) ........ ៣៧

ឧបសម្ព័ន្ធ ៥. ការវាយតម្លៃលើលទ្ធផលនៃប្រមូលសំណាក និងលទ្ធផលវិភាគ សម្រាប់ NRMP (ទម្រង់ទី៥) ........ ៣៨

ឧបសម្ព័ន្ធ ៦. គំរូមាតិកានៃរបាយការណ៍តាមដាននិងត្រួតពិនិត្យប្រចាំខែ និងត្រីមាស ........ ៣៩

ឧបសម្ព័ន្ធ ៧. គំរូមាតិកានៃរបាយការណ៍តាមដាននិងត្រួតពិនិត្យប្រចាំឆ្នាំ ........ ៤០

ឧបសម្ព័ន្ធ ៨. គំរូរបាយការណ៍ស្តីពីការពិនិត្យផ្ទៀងផ្ទាត់លើការអនុវត្ត NRMP ........ ៤១

ឧបសម្ព័ន្ធ ៩. គំរូរបាយការណ៍ស្តីពីលទ្ធផលនៃស៊ើបអង្កេតភាពមិនអនុលោម ........ ៤២

ឧបសម្ព័ន្ធ ១០. បញ្ជីពិនិត្យផ្ទៀងផ្ទាត់ការអនុវត្តវារីវប្បកម្មល្អ (GAqP Checklist) ........ ៤៣

# ពាក្យបំព្រួញ

| | |
|---|---|
| DAD | Department of Aquaculture Development (នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម) |
| DFPTQ | Department of Fisheries Post-harvest Technologies and Quality Control (នាយកដ្ឋានបច្ចេកវិទ្យាកែច្នៃ និងគុណភាព) |
| FiA | Fisheries Administration (រដ្ឋបាលជលផល) |
| IMS | Information Management System (ប្រព័ន្ធគ្រប់គ្រងព័ត៌មាន) |
| I-Team | Inspection team (ក្រុមការងារអធិការកិច្ច) |
| LOD | Limit of detection (ដែនកំណត់នៃការរកឃើញ) |
| MAFF | Ministry of Agriculture, Forestry and Fisheries (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) |
| MRL | Maximum Residues Limits (ដែនកំណត់នៃកម្រិតសំណល់អតិបរិមា) |
| NRMP | National Residues Monitoring Plan (ផែនការជាតិសម្រាប់តាមដាន និងត្រួតពិនិត្យសំណល់) |
| NRMP-C | Committee for National Residues Monitoring Plan (គណៈកម្មាធិការសម្រាប់កម្មវិធីជាតិតាមដាននិងត្រួតពិនិត្យសំណល់ឱសថវារីសត្វ) |
| NRMP-T | Operation Team for National Residues Monitoring Plan (ក្រុមការងារប្រតិបត្តិសម្រាប់កម្មវិធីជាតិតាមដាននិងត្រួតពិនិត្យសំណល់ឱសថវារីសត្វ) |
| OIC | Official In-Charge (អ្នកទទួលខុសត្រូវផ្លូវការ) |
| RPA | Reference Point of Action (ចំណុចយោងនៃសកម្មភាព) |
| SOP | Standard Operation Procedure (ស្តង់ដារប្រតិបត្តិ) |
| S-Team | Sampling team (ក្រុមការងារប្រមូលសំណាក) |
| WOAH | World Organization for Animal Health (អង្គការពិភពលោកសម្រាប់សុខភាពសត្វ) |
| UNIDO | United Nations Industrial Development Organization (អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម) |

## ១. សេចក្ដីផ្ដើម

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បញ្ហាសំណល់ឱសថវារីសត្វ និងសារធាតុគីមីផ្សេងៗ ដែលត្រូវបានប្រើក្នុងវារីវប្បកម្ម បានក្លាយជាការព្រួយបារម្ភនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ដែលចាំបាច់ត្រូវគិតគូរ និងមានដំណោះស្រាយ។ ការព្រួយបារម្ភលើការប្រើឱសថវារីសត្វ និងសំណល់សារធាតុគីមីដែលទាក់ទងជាចម្បងទៅនឹងសុវត្ថិភាពម្ហូបអាហារ និងលទ្ធភាពនៃការវិវត្តន៍របស់ភ្នាក់ងារបង្ករោគដែលបង្កឱ្យមានភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (AMR) ទន្ទឹមគ្នានេះក៏បានបង្កើនចំណាប់អារម្មណ៍ពីរដ្ឋាភិបាលនៃប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនចំពោះលក្ខខណ្ឌតម្រូវសម្រាប់ការធ្វើពាណិជ្ជកម្មអន្តរជាតិ។

ឱសថវារីសត្វត្រូវបានប្រើដើម្បីព្យាបាលជំងឺវារីសត្វ ហើយសំណល់នៃឱសថវារីសត្វទាំងនេះត្រូវបានឆ្លងចូលទៅក្នុងអាហារដែលផលិតចេញពីវារីសត្វ នឹងអាចបង្កគ្រោះថ្នាក់ដល់សុខភាព និងសុវត្ថិភាពម្ហូបអាហារដល់មនុស្ស។ ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ បាននិងកំពុងក្លាយជាប្រធានបទសំខាន់មួយនៅក្នុងពិភពលោកដោយសារមានការកើនឡើងជាលំដាប់នៃចំនួនភ្នាក់ងារបង្កជំងឺដែលបង្ហាញឱ្យឃើញពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគជាច្រើនប្រភេទ។ ការប្រើប្រាស់ឱសថវារីសត្វដោយខុសច្បាប់ និងលើសលប់ក្នុងវារីវប្បកម្មអាចមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន។ ការលេចចេញនូវបញ្ហាទាក់ទងនឹងភាពស៊ាំនឹងឱសថនេះបាននិងកំពុងជំរុញឱ្យរដ្ឋាភិបាលនៃប្រទេសនីមួយៗត្រូវបង្កើតច្បាប់ជាបន្តបន្ទាប់ សម្រាប់គ្រប់គ្រង និងត្រួតពិនិត្យលើការប្រើប្រភេទឱសថអង់ទីប៊ីយ៉ូទិកនៅក្នុងវារីវប្បកម្ម។ ទន្ទឹមគ្នានេះដែរ ការយកចិត្តទុកដាក់របស់សាធារណៈជនលើភាពស៊ាំនឹងឱសថវារីសត្វដែលបានផ្លាស់ប្ដូរទៅឧប្បត្តិហេតុចំពោះសុខភាពរបស់មនុស្ស និងបញ្ហាសុវត្ថិភាពម្ហូបអាហារដែលបណ្ដាលមកពីការប្រើឱសថវារីសត្វដែលបង្កឱ្យមានសំណល់ក្នុងផលវារីវប្បកម្ម។

ឱសថវារីសត្វរួមទាំងសមាសធាតុដែលមិនមានការអនុញ្ញាត និងមិនមានការត្រួតពិនិត្យ ជារឿយៗ អ្នកប្រើប្រាស់អាចទិញបានយ៉ាងងាយស្រួលពីគ្រប់ទីកន្លែងនៅជនបទ ឬពីអ្នកលក់ក្រៅផ្លូវការផ្ទាល់ ដែលអាចបណ្ដាលឱ្យមានបញ្ហាចំពោះការប្រើប្រាស់ ដូចជាអ្នកប្រើប្រាស់គ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សម្រាប់ការប្រើប្រាស់ ឬការប្រើប្រាស់ឱសថវារីសត្វហួសកម្រិត ព្រមទាំងកំណត់ត្រាមិនបានល្អ ដូចជាការព្យាបាល ការកំណត់អត្តសញ្ញាណ និងតាមដានវារីសត្វនីមួយៗ មិនបានត្រឹមត្រូវ ដោយមិនអនុលោមតាមបទដ្ឋានបច្ចេកទេស។

វារីវប្បកម្មមានតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់ផលជលផលឱ្យមាននិរន្តរភាព និងបំពេញតម្រូវការទីផ្សារទាំងក្នុងនិងក្រៅប្រទេស។ បច្ចុប្បន្ន វិស័យនេះមានការរីកចម្រើនយ៉ាងឆាប់រហ័សនៅក្នុងបណ្ដាប្រទេសជាសមាជិកអាស៊ានរួមទាំងប្រទេសកម្ពុជាផងដែរ។ ការធ្វើពាណិជ្ជកម្មអន្តរជាតិទាមទារឱ្យមានការគ្រប់គ្រងនិងត្រួតពិនិត្យលើការប្រើប្រាស់និងសំណល់នៃសារធាតុគីមីរួមទាំងឱសថអង់ទីប៊ីយ៉ូទិក ថ្នាំសំលាប់សត្វល្អិត អ័រម៉ូន និងឱសថវារីសត្វដែលបានប្រើប្រាស់សម្រាប់ការពារសុខភាពសត្វ ការថែរក្សាគុណភាពទឹក ការលាងសម្អាត ការលើកកម្ពស់ផលិតផល និងការកែលម្អផលិតកម្ម។ល។ ដែលតម្រូវឱ្យបណ្ដាប្រទេសអាស៊ានមានការប្រើប្រាស់សារធាតុគីមីមានភាពខុសប្លែកគ្នាយ៉ាងខ្លាំង ទាំងបរិមាណ និងទម្រង់នៃការប្រើប្រាស់ក៏ខុសគ្នារវាងប្រទេសនីមួយៗ អាស្រ័យតាមប្រតិបត្តិការវារីវប្បកម្មរបស់ពួកគេ។ ឧទាហរណ៍ ឱសថអង់ទីប៊ីយ៉ូទិកអាចត្រូវបានប្រើនៅក្នុងការព្យាបាលវារីសត្វដែលបង្កជំងឺដោយបាក់តេរីយ៉ាងមានប្រសិទ្ធភាព ប៉ុន្តែមិនមែនសម្រាប់ការលើកកម្ពស់ការលូតលាស់នោះទេ។ ម៉្យាងវិញទៀត ភាពស៊ាំនឹងជីវៈគីមី និងថ្នាំសម្លាប់សត្វល្អិតដែលត្រូវបានប្រើប្រាស់នៅក្នុងឧស្សាហកម្មផលិតកម្មសត្វសម្រាប់ព្យាបាលប៉ារ៉ាស៊ីតមួយចំនួន ប៉ុន្តែប្រតិបត្តិការក្នុងវារីវប្បកម្មស្ទើរតែគ្មានសារធាតុសកម្មសម្រាប់ការព្យាបាលជំងឺសិប្បសត្វ ឬបាណង្គសត្វនោះទេ។ ប្រភេទឱសថមួយចំនួនត្រូវបានហាមឃាត់សម្រាប់ការប្រើក្នុងផលិតផលសត្វជាអាហារ ដោយសារតែផលប៉ះពាល់នៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគ

(AMR) ដែលជាការគំរាមកំហែងកំពុងកើតមានឡើង ចំពោះសុខភាពសាធារណៈជាមួយនឹងការប្រើប្រាស់ឱសថអង់ទីប៊ីយ៉ូទិករីករាលដាលយ៉ាងទូលំទូលាយសម្រាប់ការព្យាបាលទាំងមនុស្ស និងសត្វ។

ដើម្បីធានាសុវត្ថិភាព និងអនាម័យលើផលវារីវប្បកម្ម រដ្ឋាភិបាលនិងស្ថាប័នពាក់ព័ន្ធបានបង្កើតច្បាប់ និងបទប្បញ្ញត្តិសម្រាប់ការប្រើឱសថវារីសត្វទាំងនេះឱ្យបានត្រឹមត្រូវ អនុលោមតាមបទដ្ឋានបច្ចេកទេសអន្តរជាតិ។ ដូច្នេះ ចាំបាច់ត្រូវមានការត្រួតពិនិត្យបរិមាណនៃឱសថវារីសត្វដែលនៅសេសសល់ក្នុងផល ផលិតផលជលផលនៅចន្លោះពេលទៀងទាត់ ដើម្បីវាយតម្លៃថាតើបទប្បញ្ញត្តិបាននាំឱ្យការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពចំពោះសុវត្ថិភាពម្ហូបអាហារ ការការពារ និងដំណោះស្រាយភ្លាមៗដែលទាក់ទងនឹងបញ្ហាខាងលើនេះ។ ការបង្កើតឱ្យមាននូវ**កម្មវិធីជាតិសម្រាប់តាមដាននិងត្រួតពិនិត្យលើសំណល់ឱសថវារីសត្វ និងសារធាតុគីមីក្នុងវារីវប្បកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា** (NRMP) គឺដំណោះស្រាយចាំបាច់សម្រាប់កាត់បន្ថយផលប៉ះពាល់ទាំងនេះ ដើម្បីធ្វើការត្រួតពិនិត្យ និងវាយតម្លៃសំណល់ឱសថវារីសត្វ និងសារធាតុគីមីដែលបាននិងកំពុងប្រើប្រាស់នាពេលបច្ចុប្បន្នក្នុងទិសដៅចូលរួមធ្វើសុខដុមរមនីយកម្មនៃគោលការណ៍ណែនាំ បច្ចេកទេសស្តីពីការតាមដាននិងត្រួតពិនិត្យសំណល់ឱសថវារីសត្វអន្តរជាតិ។

## ២. គោលបំណង

គោលការណ៍ណែនាំនេះ មានគោលបំណង ដើម្បីផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ការបង្កើតកម្មវិធីជាតិតាមដាន និងត្រួតពិនិត្យសំណល់ឱសថវារីសត្វ និងការបំពុលបរិស្ថានក្នុងវារីវប្បកម្ម ស្របតាមគោលការណ៍ណែនាំបច្ចេកទេស និងស្តង់ដារប្រតិបត្តិរបស់គណៈកម្មាធិការកូដិចអន្តរជាតិ (CODEX ALEMENTARIUS) និងក្រមសុខភាពវារីសត្វរបស់អង្គការសុខភាពសត្វពិភពលោក (WOAH) ។

## ៣. វិសាលភាព

គោលការណ៍ណែនាំនេះត្រូវបានរៀបចំឡើងដោយរដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយអង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម (UNIDO) ក្នុងទិសដៅការពារសុខភាពសាធារណៈ និងបំពេញនូវលក្ខខណ្ឌតម្រូវរបស់ប្រទេសនាំចូល រួមទាំងសហភាពអ៊ឺរ៉ុប ដើម្បីជំរុញការនាំចេញផល ផលិតផលជលផលកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ។

គោលការណ៍ណែនាំនេះមានវិសាលភាពអនុវត្តចំពោះការតាមដាននិងត្រួតពិនិត្យសំណល់ឱសថវារីសត្វ ឱសថប្រឆាំងមេរោគ (អង់ទីប៊ីយ៉ូទិក) និងប្រភេទអ័រម៉ូនផ្សេងៗទៀត ព្រមទាំងសំណល់សារធាតុគីមីហាមឃាត់ដែលអាចត្រូវបានប្រើក្នុងកសិដ្ឋានវារីវប្បកម្មនិងទីតាំងផលិតពាក់ព័ន្ធផ្សេងទៀត។

## ៤. ការរៀបចំទូទៅ

### ៤.១ ការបង្កើតគណៈកម្មាធិការគ្រប់គ្រង NRMP

គណៈកម្មាធិការសម្រាប់កម្មវិធីជាតិតាមដាននិងត្រួតពិនិត្យសំណល់ឱសថវារីសត្វ (NRMP-C) ត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់រដ្ឋបាលជលផល។

**ក. សមាសភាព៖**

NRMP-C ត្រូវមានសមាសភាពដូចខាងក្រោម៖

- ប្រធានរដ្ឋបាលជលផល ឬតំណាង ជា ប្រធាន
- ប្រធាននាយកដ្ឋានបច្ចេកវិទ្យាកែច្នៃ និងគុណភាព (DFPTQ) អនុប្រធាន
- ប្រធាននាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម (DAD) អនុប្រធាន
- ប្រធាននាយកដ្ឋានផែនការ គណនី និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន
- អនុប្រធាននាយកដ្ឋាន DFPTQ (១រូប) សមាជិក
- អនុប្រធាននាយកដ្ឋាន DAD (១រូប) សមាជិក
- ប្រធានការិយាល័យត្រួតពិនិត្យគុណភាព សុវត្ថិភាពនៃ DFPTQ សមាជិកអចិន្ត្រៃ
- ប្រធានការិយាល័យគ្រប់គ្រងសុខភាពនិងជំងឺវារីសត្វនៃ DAD សមាជិក
- ប្រធានការិយាល័យវារីវប្បកម្មទឹកសាបនៃ DAD សមាជិក
- ប្រធានការិយាល័យស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យានៃ DFPTQ សមាជិក

**ខ. ការទទួលខុសត្រូវ៖**

NRMP-C មានភារកិច្ចទទួលខុសត្រូវដូចខាងក្រោម៖

- ពិនិត្យផ្ទៀងផ្ទាត់សំណើគម្រោងប្រចាំឆ្នាំ មុនថ្ងៃទី៣១ ខែតុលា ជារៀងរាល់ឆ្នាំ
- រកប្រភពថវិកាសម្រាប់ការអនុវត្តកម្មវិធីជាតិសម្រាប់តាមដាននិងត្រួតពិនិត្យសំណល់ឱសថវារីសត្វ
- អនុម័តលើផែនការប្រចាំឆ្នាំ
- ពិនិត្យនិងអនុម័តលើលទ្ធផលនៃការជ្រើសរើសនិងកំណត់មន្ទីរពិសោធន៍
- ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ឬអនុសារណៈនៃការយោគយល់ដែលពាក់ព័ន្ធ
- ពិនិត្យ សម្រេច និងចុះហត្ថលេខាលើរបាយការណ៍ប្រចាំឆ្នាំ
- ជូនដំណឹងទៅកសិដ្ឋានវារីវប្បកម្ម ឬទីតាំងកែច្នៃដែលរកឃើញលទ្ធផលមិនអនុលោម
- ធ្វើការសម្រេចចិត្តលើលទ្ធផលចុងក្រោយនៃលទ្ធផលវិភាគពីកសិដ្ឋាន ឬទីតាំងកែច្នៃដែលរកឃើញថាលទ្ធផលមិនអនុលោម
- បញ្ជូនរបាយការណ៍ទៅដៃគូអភិវឌ្ឍន៍ ឬអង្គភាព ឬស្ថានប័នពាក់ព័ន្ធ
- ធ្វើការពិនិត្យផ្ទៀងផ្ទាត់ និងបច្ចុប្បន្នភាពលើការគ្រប់គ្រងនិងត្រួតពិនិត្យសំណល់ឱសថវារីសត្វ។

**៤.២ ការបង្កើតក្រុមការងារប្រតិបត្តិ NRMP**

ក្រុមការងារប្រតិបត្តិសម្រាប់កម្មវិធីជាតិតាមដាននិងត្រួតពិនិត្យសំណល់ឱសថវារីសត្វ (NRMP-T) ត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់រដ្ឋបាលជលផល។

**ក. សមាសភាព៖**

NRMP-T ត្រូវមានសមាសភាពដូចខាងក្រោម៖

- ប្រធាននាយកដ្ឋានបច្ចេកវិទ្យាកែច្នៃ និងគុណភាព (DFPTQ) ឬតំណាង ជា ប្រធាន

- អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម (១រូប) អនុប្រធាន
- អនុប្រធាននាយកដ្ឋានបច្ចេកវិទ្យាកែច្នៃ និងគុណភាព (១រូប) អនុប្រធាន
- មន្ត្រីនៃនាយកដ្ឋានបច្ចេកវិទ្យាកែច្នៃ និងគុណភាព (ចំនួន) សមាជិក
- មន្ត្រីនៃនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម (ចំនួន) សមាជិក
- មន្ត្រីនៃខណ្ឌរដ្ឋបាលជលផល (ចំនួន) សមាជិក

បញ្ជាក់៖ ចំនួននៃមន្ត្រីជាសមាជិក សម្រាប់ក្រុមការងារត្រូវជ្រើសរើសអាស្រ័យតាមតម្រូវការជាក់ស្តែង។

**ខ. ការទទួលខុសត្រូវ៖**

NRMP-T មានភារកិច្ចទទួលខុសត្រូវដូចខាងក្រោម៖
- រៀបចំផែនការ និងថវិកាប្រចាំឆ្នាំ ឱ្យបានមុខថ្ងៃទី៣០ ខែកញ្ញា ជារៀងរាល់ឆ្នាំ
- បញ្ជូនផែនការ និងថវិកាប្រចាំឆ្នាំ ទៅ NRMP-C ដើម្បីស្នើសុំការអនុម័ត
- រៀបចំផែនការសកម្មភាព និងតារាងប្រតិទិនសម្រាប់ការប្រមូល និងវិភាគសំណាក
- បង្កើតនិងចាត់ចែង ក្រុមការងារប្រមូលសំណាក (S-Team) និងក្រុមការងារអធិការកិច្ច (I-Team)
- សហការជាមួយខណ្ឌរដ្ឋបាលជលផល ក្នុងការចុះប្រមូលសំណាក
- ទំនាក់ទំនងនិងជូនដំណឹងទៅមន្ទីរកសិកម្ម កសិដ្ឋានវារីវប្បកម្ម និងអ្នកពាក់ព័ន្ធ
- ទំនាក់ទំនងជាមួយមន្ទីរពិសោធន៍ស្តីពីតម្រូវការវិភាគ និងលក្ខខណ្ឌតម្រូវចាំបាច់
- រៀបចំសំណាកនិងផ្ញើរទៅមន្ទីរពិសោធន៍
- អង្កេត និងត្រួតពិនិត្យសារឡើងវិញនូវកសិដ្ឋានវារីវប្បកម្ម ឬទីតាំងកែច្នៃដែលមិនអនុលោម
- រក្សាទុកនូវទិន្នន័យ និងលទ្ធផលវិភាគឱ្យបានសមរម្យ
- រៀបចំរបាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំ
- រៀបចំកិច្ចប្រជុំ ដើម្បីពិនិត្យនិងពិភាក្សាលើការងារប្រចាំសប្តាហ៍ ខែ និងឆ្នាំ
- ពិនិត្យផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពផែនការ ដើម្បីអនុវត្តន៍បន្ត
- ការងារផ្សេងៗទៀត ដែល NRMP-C ប្រគល់ជូន។

## ៤.៣ ការជ្រើសរើសនិងកំណត់យកមន្ទីរពិសោធន៍

ការវិភាគសំណាកសម្រាប់រកសំណល់ឱសថវារីសត្វ និងការបំពុលបរិស្ថាន ចាំបាច់ត្រូវធ្វើឡើងនៅក្នុងមន្ទីរពិសោធន៍ដែលមានស្តង់ដារ ISO17025 ដោយអនុវត្តន៍តាមប៉ារ៉ាម៉ែត្រតេស្តដែលត្រូវការ។ ក្នុងករណីចាំបាច់ ប្រធាន NRMP-T មានសិទ្ធិសម្រេចកំណត់ជ្រើសរើសយកមន្ទីរពិសោធន៍ខាងក្រៅប្រទេសដែលមានការទទួលស្គាល់ដោយស្តង់ដារ ISO17025 និងមានសមត្ថភាពធ្វើវិភាគលើសំណាកសម្រាប់រកសំណល់ឱសថវារីសត្វ និងសារធាតុកខ្វក់ពីបរិស្ថាន ស្របតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារអន្តរជាតិ។

ដូច្នេះ ការជ្រើសរើសនិងកំណត់មន្ទីរពិសោធន៍ខាងក្រៅ ត្រូវផ្អែកលើកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរប្រចាំឆ្នាំ តាមរយៈផែនការប្រចាំឆ្នាំ។ កិច្ចព្រមព្រៀងត្រូវរួមបញ្ចូលយ៉ាងហោចណាស់ដូចខាងក្រោម៖

**ព័ត៌មានដែលត្រូវបញ្ជូនដោយក្រុមការងារប្រតិបត្តិ**

- ចំនួនសំណាកក្នុងមួយឆ្នាំ (តាមខែនីមួយៗ)

- ប្រភេទនៃសំណាក/ម៉ាទ្រីសសម្រាប់ការវិភាគ
- លក្ខខណ្ឌនៃសំណាក (ចំនួនសរុប ស្រស់/បង្កក)
- ក្រុមនៃសារធាតុគីមី និងប៉ារ៉ាម៉ែត្រដែលត្រូវវិភាគក្នុងមួយសំណាក

**ព័ត៌មានដែលត្រូវបញ្ជូនដោយមន្ទីរពិសោធន៍**
- វិធីសាស្ត្រវិភាគ និងបញ្ជាក់
- ដែនកំណត់នៃការរកឃើញ (LOD) សម្រាប់វិធីសាស្ត្របញ្ជាក់
- គោលការណ៍វិភាគសម្រាប់វិធីសាស្ត្រ (ប្រសិនបើប្រើ)
- ដែនកំណត់នៃការរកឃើញ (LOD) សម្រាប់វិធីសាស្ត្រវិភាគ (ប្រសិនបើប្រើ)
- ការបញ្ជាក់ថាវិធីសាស្ត្រដែលបានយល់ព្រម ដើម្បីប្រើប្រាស់ គឺស្ថិតនៅក្នុងវិសាលភាពនៃការទទួលស្គាល់ដោយមន្ទីរពិសោធន៍ រួមជាមួយព័ត៌មានអំពីស្ថាប័ន និងស្ថានភាពនៃការទទួលស្គាល់
- ការប៉ាន់ប្រមាណតម្លៃដោយផ្អែកលើព័ត៌មានដែលផ្តល់ដោយ NRMP-T
- ព័ត៌មានអំពីការអនុវត្តក្នុងការធ្វើតេស្តសមត្ថភាពសម្រាប់វិធីសាស្ត្រដែលបានបញ្ជាក់អាចនឹងត្រូវបានស្នើសុំផងដែរ ក្នុងករណីចាំបាច់។ ប្រសិនបើមិនមានការចាំបាច់ទេ ព័ត៌មានអំពី សុពលភាព និងការត្រួតពិនិត្យគុណភាពផ្ទៃក្នុង (ការត្រួតពិនិត្យ និងតារាងត្រួតពិនិត្យវិជ្ជមាន និងអវិជ្ជមាន) នឹងត្រូវទាមទារឱ្យមាន។

**ត្រូវយល់ព្រមដោយភាគីទាំងពីរ (យ៉ាងហោចណាស់)**
- បង្កើតមន្ត្រីទំនាក់ទំនង (ឈ្មោះអ្នកទទួលខុសត្រូវ និងអាសយដ្ឋានអ៊ីមែល/លេខទូរស័ព្ទ)
- លក្ខខ័ណ្ឌសម្រាប់ការបែងចែកសំណាក
- ការដឹកជញ្ជូន វិធីសាស្ត្រ និងការជូនដំណឹងជាមុន
- ចំនួនថ្ងៃក្នុងសប្តាហ៍ដើម្បីទទួលបានសំណាក
- ពេលវេលាដើម្បីផ្តល់លទ្ធផលវិភាគ បន្ទាប់ពីទទួលបានសំណាក (១ អតិបរមា ២ សប្តាហ៍)
- របាយការណ៍ និងវិធីសាស្ត្រនៃការដឹកជញ្ជូន (អេឡិចត្រូនិក និង/ឬក្រដាស)
- តម្លៃសម្រាប់សេវាកម្មពេញមួយឆ្នាំ
- លក្ខខណ្ឌក្នុងការចេញវិក្កយបត្រ និងការទូទាត់

## ៥. ស្តង់ដារប្រតិបត្តិ ( SOP )

### ៥.១ ការរៀបចំផែនការប្រចាំឆ្នាំ

| | |
|---|---|
| អ្វី?<br>What? | ការសម្រេចចិត្តលើទំហំការងារនៃ NRMP សម្រាប់ឆ្នាំបន្ទាប់ ដោយបានគិតទាំងទីតាំងកែច្នៃ និងកសិដ្ឋានវារីវប្បកម្ម ព្រមទាំងប្រភេទវារីសត្វដែលនឹងត្រូវអនុម័តនិងដាក់បញ្ចូលក្នុងផែនការប្រចាំឆ្នាំ។ |

| | |
|---|---|
| **ហេតុអ្វី/ គោលបំណង?** Why/Objective | កំណត់ចំនួនសំណាក និងសមាសធាតុគីមី (ប៉ារ៉ាម៉ែត្រ) ដែលត្រូវធ្វើតេស្តពីប្រភេទគោលដៅក្នុងគោបំណង៖<br>- តាមដានសក្តានុពលនៃការប្រើឱសថវ៉ារីសត្វហាមឃាត់<br>- តាមដានការប្រើខុសបច្ចេកទេស ឬ ប្រើឱសថវ៉ារីសត្វដែលត្រូវបានអនុញ្ញាត និង<br>- រកវត្តមានសារធាតុគីមីដែលលើសតម្រិតកំណត់ដែលអាចកើតមាននៅក្នុងផលជលផល និងជះឥទ្ធិពលដល់ការបំពុលបរិស្ថាន។ |
| **នរណា?** Who | ក្រុមការងារប្រតិបត្តិសម្រាប់កម្មវិធីជាតិតាមដាននិងត្រួតពិនិត្យសំណល់ឱសថវ៉ារីសត្វ (NRMP-T)។ |
| **ពេលណា?** When | មុនថ្ងៃទី៣០ ខែកញ្ញា ជារៀងរាល់ឆ្នាំ ។ |
| **យ៉ាងដូចម្តេច?** How | កំណត់ទិន្នន័យចាំបាច់ យ៉ាងហោចណាស់មានដូចខាងក្រោម៖<br>- ចំនួនកសិដ្ឋាន ទីតាំង និងអាស័យដ្ឋាន<br>- ទំហំតាមកសិដ្ឋាន<br>- ពូជវ៉ារីសត្វមាននៅក្នុងកសិដ្ឋាន<br>- បរិមាណផលិតរបស់កសិដ្ឋាន<br>- ចំនួនវដ្តនៃផលិតកម្ម<br>- ប្រភពចំណីតាមកសិដ្ឋាន<br>- លទ្ធផលឆ្នាំមុន<br>- ច្បាប់/សេចក្តីណែនាំថ្មីៗពីទីផ្សារ ឬអង្គការធំៗ (Codex, OIE, EU, ASEAN, US) ដែលអាចមានផលប៉ះពាល់<br>- ច្បាប់ថ្មីរបស់កម្ពុជាដែលត្រូវបានចុះហត្ថលេខា ឬកំពុងដំណើរការដែលអាចមានផលប៉ះពាល់។<br><br>ប្រមូលទិន្នន័យផលិតកម្មពី៖<br>- ស្ថិតិផលជលផល (នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងសហប្រតិបត្តិការអន្តរជាតិ)<br>- ការចុះបញ្ជីកសិដ្ឋាន/អាជ្ញាប័ណ្ណ (នាយកដ្ឋានអភិវឌ្ឍន៍វ៉ារីវប្បកម្ម)<br>- ការចុះបញ្ជិកាសម្រាប់កសិដ្ឋាន (ខណ្ឌរដ្ឋបាលជលផល)<br>- ព័ត៌មានអំពីអ្នកផ្គត់ផ្គង់វត្ថុធាតុដើម និងពីរោងចក្រកែច្នៃដែលត្រូវបានអនុម័ត/ចុះបញ្ជី។<br>- |
| **ទម្រង់ដែលត្រូវប្រើ** Form to use | Excel sheet forms សម្រាប់ផែនការប្រចាំឆ្នាំ ទម្រង់ ក១, ក២, ក៣, និងក៤ រួមជាមួយតារាងទិន្នន័យសម្រាប់ចំនួនសំណាកនិងប៉ារ៉ាម៉ែត្រត្រូវធ្វើវិភាគ (ឧបសម្ព័ន្ធ ១) |

**វិធានទី១៖** ការរៀបចំផែនការប្រចាំឆ្នាំនៃកម្មវិធីជាតិសម្រាប់តាមដាននិងត្រួតពិនិត្យសំណល់ឱសថវារីសត្វ និងសារធាតុគីមីក្នុងផលវារីវប្បកម្ម និងការបំពុលបរិស្ថាន។



## ៥.២ ការរៀបចំផែនការសកម្មភាពលម្អិត

| | |
|---|---|
| **អ្វី?**<br>What? | រៀបចំផែនការប្រមូលសំណាកលម្អិតក្នុងខែនីមួយៗ ដោយគិតពិចារណាលើព័ត៌មានលម្អិតដែលមាននៅក្នុងផែនការជាតិប្រចាំឆ្នាំ។ |
| **ហេតុអ្វី/ គោលបំណង?**<br>Why/Objective | ត្រូវប្រាកដថា ចំនួនសំណាកដែលបានគ្រោងទុក ទីកន្លែងប្រមូលសំណាកនៅក្នុងខ្សែសង្វាក់តម្លៃ និងប្រភេទសំណាក ត្រូវអនុវត្តនិងយោងតាមផែនការជាតិ។ |
| **នរណា?**<br>Who | NRMP-T (ក្នុងកិច្ចសហការជាមួយខណ្ឌរដ្ឋបាលជលផល) |
| **ពេលណា?**<br>When | ត្រូវឱ្យបានមុនថ្ងៃទី៣០ ខែកញ្ញា ជារៀងរាល់ឆ្នាំ ។ |
| **យ៉ាងដូចម្តេច?**<br>How | ○ អនុវត្តដោយយោងតាមចំនួនសំណាក និងប៉ារ៉ាម៉ែត្រដែលត្រូវធ្វើតេស្តដូចគ្រោងទុកក្នុងផែនការជាតិ។<br>○ ប្រមូលទិន្នន័យអំពីវដ្តផលិតកម្មសម្រាប់កសិដ្ឋានវារីវប្បកម្មពាក់ព័ន្ធ និងប្រភេទវារីសត្វពីមន្ត្រីជំនាញជលផលក្នុងស្រុក។<br>○ បង្កើតផែនការប្រចាំឆ្នាំដោយកំណត់ចំនួនសរុបក្នុងមួយខែសម្រាប់គំរូដែលត្រូវអនុវត្តក្នុងមួយកសិដ្ឋាន សហគ្រាស ប្រភេទគំរូ និងប៉ារ៉ាម៉ែត្រដែលត្រូវធ្វើតេស្ត។<br>○ ត្រូវប្រាកដថា ការធ្វើតេស្តសម្រាប់<br>- សារធាតុគីមីក្រុម A នឹងត្រូវបានអនុវត្តចំពោះសំណាកដែលបានយកពីកសិដ្ឋានពេញមួយវដ្តផលិតកម្ម<br>- សារធាតុគីមីក្រុម B ថ្នាំសម្លាប់សត្វល្អិត និងសារធាតុបំពុលបរិស្ថាន នឹងត្រូវអនុវត្តចំពោះសំណាកដែលយកពីកសិដ្ឋាន ឬសហគ្រាសកែច្នៃជលផលដែលត្រៀមដាក់លក់នៅលើទីផ្សារ។ |
| **ទម្រង់ដែលត្រូវប្រើ**<br>Form to use | Excel sheet ទម្រង់ ខ១, ខ២, ខ៣ និង ខ៤ សម្រាប់លទ្ធផលវិភាគ ប្រៀបធៀបនឹងផែនការប្រចាំឆ្នាំ (ឧបសម្ព័ន្ធ ២) |

## ៥.៣ ការប្រមូល និងវិភាគសំណាក

រដ្ឋបាលជលផលនឹងធ្វើការទំនាក់ទំនងជាមួយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចូល ដើម្បីរាយការណ៍អំពីផែនការប្រចាំឆ្នាំនៃកម្មវិធីជាតិសម្រាប់ការតាមដាននិងត្រួតពិនិត្យសំណល់ឱសថវារីសត្វ (NRMP) និងរបាយការណ៍ស្តីពីលទ្ធផលនៃ NRMP ក្នុងករណីមានការតម្រូវ។ ចំពោះផែនការជាតិ (NRMP) នេះ ចាំបាច់ត្រូវអនុវត្តការតាមដាននិងត្រួតពិនិត្យយ៉ាងតិចរយៈពេល ១០ ខែក្នុងមួយឆ្នាំ ដែលចាប់ផ្តើមចន្លោះពីខែមករា រហូតដល់ខែធ្នូ។ ក្នុងករណីមានការមិនអនុលោម ដោយផ្អែកលើទិន្នន័យស្តីពីលទ្ធផលនៃកម្មវិធីជាតិ (NRMP) រដ្ឋបាលជលផល ត្រូវចាត់វិធានការនានាចាំបាច់ ដើម្បីកាត់បន្ថយការមិនអនុលោមនេះ តាមរយៈការផ្តល់ជំនួយបច្ចេកទេសបន្ថែម ការបណ្តុះបណ្តាល និងរៀបចំកម្មវិធីយល់ដឹងសម្រាប់អ្នកពាក់ព័ន្ធ។

| | |
|---|---|
| អ្វី?<br>What? | ការប្រមូលយកសំណាកនិងបញ្ជូនសំណាកទៅមន្ទីរពិសោធន៍ ព្រមទាំងការរៀបចំនិងបញ្ជូនលទ្ធផលនៃសំណាក និងលទ្ធផលនៃការវាយតម្លៃ GAqP ទៅ NRMP-T។ |
| ហេតុអ្វី/គោលបំណង?<br>Why/Objective | ធានាការអនុវត្តផែនការជាតិដូចការរំពឹងទុក ជាពិសេសធានាការទំនាក់ទំនងនៃលទ្ធផលដែលមិនអនុលោមតាម GAqP ទៅកាន់ NRMP-T។ |
| នរណា?<br>Who | កិច្ចសហការរវាង S-Team និង I-Team (per assignment)។ |
| ពេលណា?<br>When | ដោយផ្អែកលើមូលដ្ឋាននៃកាលវិភាគក្នុងផែនការ (មើលវិធានទី១)។ |
| យ៉ាងដូចម្តេច?<br>How | អនុវត្តតាមចំនួនសំណាក និងប៉ារ៉ាម៉ែត្រត្រូវធ្វើតេស្តដែលត្រូវបានបង្កើតក្នុងផែនការតាមដាន (មើលវិធានទី១)។<br>បញ្ជាក់ទិន្នន័យអំពីវដ្តផលិតកម្មសម្រាប់កសិដ្ឋាន និងប្រភេទវារីសត្វដែលត្រូវជ្រើសរើសជាមួយមន្ត្រីខ័ណ្ឌរដ្ឋបាលជលផល មុនពេលចាប់ផ្តើមសកម្មប្រមូលសំណាក។ អនុវត្តតាមការណែនាំការងារដូចខាងក្រោម។ |
| ទម្រង់ដែលត្រូវប្រើ<br>Form to use | ទម្រង់ទី៣ និងទម្រង់ទី៤ (ឧបសម្ព័ន្ធ ៣ និងឧបសម្ព័ន្ធ ៤), និង GAqP Checklist (ឧបសម្ព័ន្ធ ១០) |

**ការណែនាំអំពីការងារ**

ការរៀបចំចុះប្រមូលសំណាក

១. ពិនិត្យផ្ទៀងផ្ទាត់ចំនួនសំណាកត្រូវប្រមូល ចំនួនប៉ារ៉ាមែត្រ និងចំនួនកសិដ្ឋានដែលត្រូវជ្រើសរើសជាគំរូ (មើល វិធានទី១)

២. បញ្ជាក់ពីទិន្នន័យអំពីវដ្តផលិតកម្ម និងប្រព័ន្ធកសិដ្ឋាន និងសមត្ថភាព សម្រាប់កសិដ្ឋានចូលរួម និងប្រភេទវារីសត្វ ជាមួយមន្ត្រីខណ្ឌរដ្ឋបាលជលផល ប្រសិនបើចាំបាច់។

៣. ទាមទារដាក់លេខកូដសំណាក ដោយប្រធាន NRMP-T។

លេខកូដសំណាក ត្រូវបញ្ចូលនូវព័ត៌មានដូចខាងក្រោម៖

XX : ឆ្នាំ (លេខពីរខ្ទង់ ឧទា. ១២)

YY : ខែ (លេខពីរខ្ទង់ ឧទា. ០១)

Z : លេខរៀងបន្តពី១ នៃខែនីមួយៗ (យ៉ាងហោចណាស់ លេខពីរខ្ទង់, ជារៀងរាល់ខែ)

V : ប្រភេទនៃសំណាក (ឧទា. FT=Tilapia, FP=Pangasius...... )

N : តំបន់ ឬទីតាំង (ឧទា. ១=កណ្តាល, ២=បាត់ដំបង...)

S : ក្រុមនៃសមាសធាតុគីមី

លេខកូដសំណាក ត្រូវប្រើដូចខាងក្រោម៖

ឧទាហរណ៍ XXYY-Z-V-N-S ក្លាយជា ១៦០២-០១-FP២-A១ មានន័យថា សំណាកលេខរៀងទី១ ត្រូវបានប្រមូលក្នុងខែកុម្ភៈ ឆ្នាំ២០១៦, សំណាកត្រីប្រា ដែលត្រូវបានប្រមូលនៅខេត្តបាត់ដំបង និងសម្រាប់ធ្វើវិភាគក្រុមនៃសមាសធាតុគីមី A1។

៤. កំណត់ចំនួនសំណាកដែលត្រូវប្រមូលសម្រាប់ការវិភាគលើក្រុមនៃប៉ារ៉ាម៉ែត្រ។ ចំនួនសំណាកដែលត្រូវប្រមូលត្រូវផ្អែកលើចំនុច ១២ ខាងក្រោម ព្រមទាំងផែនការចុះតាមដាននិងត្រួតពិនិត្យផ្ទាល់។

៥. ផ្ទៀងផ្ទាត់របាយការណ៍នៃលទ្ធផលអំពីការប្រមូលសំណាកលើកមុន ដើម្បីពិនិត្យមើលប្រសិនបើមានបញ្ហាពិសេសដែលត្រូវពិចារណាចំពោះផែនការប្រមូលសំណាក។

៦. ប្រមូលផ្តុំឧបករណ៍បរិក្ខាចាំបាច់រួមមាន៖

- សំណាញ់
- ថ្នាំង
- ថង់ផ្លាស្ទីកថ្មី (មិនប្រើថង់ដែលបានប្រើរួច)
- ស្រោមដៃ
- កាំបិត
- ជ្រុញ
- ទឹកកក
- ធុងស្នោ
- ប៊ិច Marker
- ស្លាកមិនជ្រាបទឹក
- ខ្សែសម្រាប់ចងមាត់ថង់ មិនឱ្យចូលទឹក និងស្ទីកគ័រសម្រាប់សរសេរបិទលើថង់។

**ដំណើការប្រមូលសំណាក**

៧. ពេលចូលមកដល់ទីតាំងកសិដ្ឋាន៖ ត្រូវណែនាំខ្លួនទៅម្ចាស់កសិដ្ឋាន ឬអ្នកគ្រប់គ្រងកសិដ្ឋាន ព្រមទាំងជម្រាបអំពីគោលបំណងនៃបេសកម្ម។

៨. សួរនាំម្ចាស់កសិដ្ឋាន ឬអ្នកគ្រប់គ្រងកសិដ្ឋានអំពីចំនួន និងទំហំស្រះក្នុងកសិដ្ឋាន ប្រភេទចំណីដែលប្រើប្រាស់ និងប្រសិនបើមានកើតជំងឺ ឬហានីភ័យកើតចេះពីការពុលបរិស្ថាន អំឡុងពេលចាប់ពីបេសកម្មលើកមុន (សូមមើល GAqP Checklist)។

៩. ធ្វើការវាយតម្លៃជាសង្ខេបលើកដំបូង លើឯកសារដោយពិនិត្យផ្ទៀងផ្ទាត់ជាមួយការឆ្លើយតបរបស់ម្ចាស់កសិដ្ឋាន ឬអ្នកគ្រប់គ្រង (សូមមើល GAqP Checklist)។

១០. ធ្វើការវាយតម្លៃជាសង្ខេបតាមរយៈការមើលឃើញផ្ទាល់លើសម្ភារៈ និងការអនុវត្តជាក់ស្តែង មានជាអាទិ៍ៈ ការស្តុកចំណី, ការទុកដាក់ឱសថវារីសត្វ, ការអនុវត្តផ្តល់ចំណី (សូមមើល GAqP Checklist)។ រៀបចំឯកសារអំពីការអង្កេតជាលាល័ក្ខអក្សរ និងមានរូបភាព។

១១. ពិនិត្យផ្ទៀងផ្ទាត់ផែនការប្រមូលសំណាកដែលបានរៀបចំ ហើយសម្រេចចិត្តថាតើលទ្ធផលនៃការវាយតម្លៃជាមុន (សូមមើលចំណុចទី ៧-១០ ខាងលើ) គួរផ្តល់ឱ្យអ្នកនូវមូលហេតុដើម្បីកែតម្រូវផែនការប្រមូលយកសំណាក។

១២. ធ្វើការប្រមូលសំណាកដោយអនុវត្តតាមផែនការដើម ឬកែសម្រួល (សូមមើលចំណុច ១១ ខាងលើ)។ សំណាកនីមួយៗ ត្រូវប្រព្រឹត្តិទៅដូចខាងក្រោមៈ

- ពី ១ ស្រះ ត្រូវប្រមូលយកសំណាក ៥-១០

  - សំណាកនីមួយៗត្រូវមានទម្ងន់យ៉ាងហោចណាស់ ៥០-១០០ក្រាម ហើយអាចជាត្រី ១ ក្បាល ឬច្រើនក្បាល ឬផ្នែកកណ្តាលនៃត្រីមួយ ឬចំនួនគ្រប់គ្រាន់អាស្រ័យតាមទំហំត្រីនៅក្នុងស្រះ។
  - ប្រសិនបើត្រីមានទម្ងន់ <៣០០ក្រាម/ត្រី នោះសំណាកអាចជាត្រីទាំងមូល
  - ប្រសិនបើត្រីមានទម្ងន់ >៣០០ក្រាម/ត្រី នោះត្រូវយកផ្នែកកណ្តាលនៃត្រី ទម្ងន់ប្រហែល ១០០ ក្រាម
  - ប្រសិនបើត្រីធំជាង ១,៥ គីឡូក្រាម អាចយកត្រីមួយក្បាលធ្វើជាសំណាក និងទម្ងន់សរុប

- ការរួមបញ្ចូលសំណាកជា ១ គំរូសរុប។ គំរូសរុបត្រូវដាក់លេខកូដ (សូមមើលចំណុចទី ៣ ខាងលើ)
- គំរូសរុបត្រូវយកសាច់សុទ្ធយ៉ាងហោចណាស់ទម្ងន់ 500ក្រាម៖

  - 500ក្រាម ប្រសិនបើវិភាគសម្រាប់សមាសធាតុគីមី ក្រុម A1, A2, A3, A6, B1, B2, ថ្នាំសម្លាប់សត្វល្អិត និងសមាសធាតុសរីរាង្គអាឡូហ្សែន (halogenated organic compounds)។

១៣.ត្រូវប្រាកដថាការដាក់ស្លាកជាមួយលេខកូដសម្គាល់សំណាក និងការផ្សាភ្ជាប់នលើគំរូសរុប ធ្វើយ៉ាងណាមិនឱ្យមានហានិភ័យនៃការលេចធ្លាយ ឬការបឺតទឹកចូល ហើយធ្វើយ៉ាងណាឱ្យស្លាកសម្គាល់មានភាពច្បាស់លាស់ និងងាយស្រួលអាន។

១៤. ចងក្រងឯកសារស្តីពីការប្រមូលសំណាកគំរូ និងលទ្ធផលនៃការវាយតម្លៃ លើទម្រង់ទី៣ និង GAqP Checklist។

១៥. នៅពេលសំណាកមកដល់កន្លែង ត្រូវជូនដំណឹងភ្លាមជូនដល់ប្រធាន NRMP-T ប្រសិនបើ មានការសង្កេតលើកសិដ្ឋានអាចនាំឱ្យមានការវិភាគលើប៉ារ៉ាម៉ែត្រថ្មីផ្សេងទៀតលើសពីការគ្រោងទុក។ ការសម្រេចចិត្តចុងក្រោយចំពោះប៉ារ៉ាម៉ែត្រដែលត្រូវវិភាគក្នុងសំណាកនីមួយៗ ដែលត្រូវចងក្រងជាឯកសារដោយប្រើទម្រង់ទី៤។

## ការរៀបចំ និងបញ្ជូនសំណាកទៅមន្ទីរពិសោធន៍

១៦. សំណាកត្រូវថែរក្សាទុកដោយប្រើទឹកកក និងគ្របបិទជិត កំឡុងពេលដឹកជញ្ជូន និងផ្ទេរយ៉ាងឆាប់អាចធ្វើទៅបាន ទៅមន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាពផល ផលិតផលជលផល នៃនាយកដ្ឋានបច្ចេកវិទ្យាកែច្នៃ និងគុណភាព ដើម្បីបន្តរក្សាទុកបន្ទាប់ពីប្រមូលបាន ២-៣ថ្ងៃ។

១៧. នៅពេលប្រគល់ទៅឱ្យតំណាងមន្ទីរពិសោធន៍ត្រូវប្រើទម្រង់ផ្ទេរសំណាកគំរូ (ទម្រង់ទី៤) និងត្រូវបំពេញដោយមន្ត្រីអធិការកិច្ច និងចុះហត្ថលេខាដោយទមន្ត្រីអធិការកិច្ច និងមន្ត្រីនៃនាយកដ្ឋានបច្ចេកវិទ្យាកែច្នៃ និងគុណភាព ជាអ្នកទទួលសំណាក (សូមមើលចំណុចទី ៣ ខាងលើ)។

**វិធានទី២៖** ការប្រមូល និងវិភាគសំណាកគំរូសម្រាប់កម្មវិធីជាតិតាមដាននិងត្រួតពិនិត្យសំណល់ ឱសថវារីសត្វ និងសារធាតុគីមីក្នុងផលវារីវប្បកម្ម និងការបំពុលបរិស្ថាន។



## ៥.៤ ការរៀបចំនិងបញ្ជូនសំណាក និងការទទួលលទ្ធផលវិភាគពីមន្ទីរពិសោធន៍

| | |
|---|---|
| **អ្វី?**<br>What? | ទទួលសំណាក បង្កកសំណាក និងបញ្ជូនសំណាកដែលត្រូវបានបង្កកសម្រាប់ធ្វើវិភាគក្នុងមន្ទីរពិសោធន៍ដែលបានកំណត់។ |
| **ហេតុអ្វី/គោលបំណង?**<br>Why/Objective | ត្រូវប្រាកដថាប៉ារ៉ាម៉ែត្រ និងលក្ខណៈវិនិច្ឆ័យនៃការអនុវត្ត ត្រូវគោរពដូចដែលមានចែងក្នុងផែនការជាតិ។ |
| **នរណា?**<br>Who | មន្ត្រី DFPTQ ដែលត្រូវបានចាត់តាំង ទទួលខុសត្រូវក្នុងការទទួលនិងបញ្ជូនសំណាក ហើយចំពោះប្រធាន NRMP-T ទទួលខុសត្រូវចំពោះទំនាក់ទំនងនិងទទួលលទ្ធផល។ |
| **ពេលណា?**<br>When | បញ្ជូនសំណាកជាមួយនឹងសំណើសលើការវិភាគទៅមន្ទីរពិសោធន៍ដែលបានកំណត់ក្នុងរយៈពេល ២ សប្តាហ៍ បន្ទាប់ពីទទួលបានពី S-Team។ ត្រូវប្រាកដថា លទ្ធផលនឹងត្រូវបានផ្តល់ជូនក្នុងរយៈពេលដូចមានចែងក្នុកិច្ចសន្យាព្រមព្រៀងជាមួយមន្ទីរពិសោធន៍ដែលបានកំណត់។ |
| **យ៉ាងដូចម្តេច?**<br>How | យោងតាម ប៉ារ៉ាម៉ែត្រតេស្ត លក្ខណៈវិនិច្ឆ័យនៃការអនុវត្ត និងមន្ទីរពិសោធន៍ដែលបានកំណត់ ដូចមានចែងក្នុងផែនការជាតិ។ |
| **ទម្រង់ដែលត្រូវប្រើ**<br>Form to use | ការបញ្ជូនសំណាក តាមទម្រង់៤ (ឧបសម្ព័ន្ធ ៤) និងសៀវភៅកំណត់ហេតុស្តីពីការទទួល និងបញ្ជូនសំណាក និងការទទួលលទ្ធផល។ នៅពេលបញ្ជូនសំណាកទៅមន្ទីរពិសោធន៍ខាងក្រៅត្រូវបានភ្ជាប់ជាមួយនូវទម្រង់នៃព័ត៌មានតាមតម្រូវការដោយមន្ទីរពិសោធន៍នោះ។ |



**វិធានទី៣៖** ការវាយតម្លៃលើលទ្ធផលមន្ទីរពិសោធន៍ និងការរៀបចំលំហូរសកម្មភាព និងរបាយការណ៍ប្រចាំឆ្នាំ



## ៥.៥ ការត្រួតពិនិត្យសារឡើងវិញជាបន្ទាន់ចំពោះភាពមិនអនុលោម

| | |
|---|---|
| **អ្វី?**<br>What? | ធ្វើការស៊ើបអង្កេត ដើម្បីកំណត់អត្តសញ្ញាណដើមហេតុ និងផលប៉ះពាល់បន្ថែមទៀតចំពោះការកឃើញជាវិជ្ជមាននៃសំណល់ និងដើម្បីធ្វើការសម្រេចចិត្តលើសកម្មភាពដែលត្រូវអនុវត្ត។ |
| **ហេតុអ្វី/គោលបំណង?**<br>Why/Objective | ផ្តល់ទិន្នន័យ សម្រាប់ការសម្រេចចិត្តលើសកម្មភាពដែលត្រូវអនុវត្ត។ |
| **នរណា?**<br>Who | ក្រុម NRMP-T ត្រូវសហការជាមួយ I-Team និង S-Team និង NRMP-C ។ |
| **ពេលណា?**<br>When | ក្នុងករណី ការរកឃើញវិជ្ជមាននៃសំណល់ និងត្រូវចាប់ផ្តើមធ្វើសកម្មភាពភ្លាមៗ នៅពេលដែលការរកឃើញនូវវិជ្ជមាននៃសំណល់។ |
| **យ៉ាងដូចម្តេច?**<br>How | ត្រូវចាប់ផ្តើមធ្វើសកម្មភាពភ្លាមៗ នៅទីតាំងកសិដ្ឋាន តាមអាចធ្វើទៅបាន (សូមមើលខាងក្រោម)។ រៀបចំ និងធ្វើការអង្កេតផ្ទាល់នៅទីតាំងដែលរកឃើញវិជ្ជមាននៃសំណល់ រួមបញ្ចូលទាំងការប្រមូលយកសំណាកបន្ថែម ក្នុងករណីចាំបាច់។ |
| **ទម្រង់ដែលត្រូវប្រើ**<br>Form to use | ទម្រង់ទី៥ (ឧបសម្ព័ន្ធ ៥) |

**សកម្មភាពដែលអាចធ្វើបាន**

១. ប្រធាន NRMP-T ត្រូវបញ្ជូនរបាយការណ៍ចុងក្រោយស្តីពីប្រមូលសំណាក (ទម្រង់ទី៥) ជូនទៅ NRMP-C ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ក្នុងរយៈពេលមួយ(០១)ថ្ងៃ បន្ទាប់ពីទទួលបានលទ្ធផលនៃការរកឃើញជាវិជ្ជមាន។

២. NRMP-T ត្រូវស្នើសុំសកម្មភាពដែលត្រូវធ្វើ (សូមមើលចំណុចទី៣ ខាងក្រោម) ហើយបញ្ជូនលទ្ធផលក៏ដូចជាសកម្មភាពដែលបានស្នើទៅ NRMP-C ឱ្យបានឆាប់តាមដែលអាចធ្វើបាន ក្នុងរយៈពេលពីរ(០២) ថ្ងៃ បន្ទាប់ពីទទួលបានលទ្ធផលនៃការរកឃើញជាវិជ្ជមាន។

៣. ប្រធាន NRMP-C ត្រូវចេញការហាមឃាត់ជាបណ្តោះអាសន្នចំពោះការធ្វើចរាចរ ឬការប្រមូលផលពីកសិដ្ឋាន ដោយចេញលិខិតផ្លូវការពន្យល់អំពីមូលហេតុនៃការហាមឃាត់ដោយយោងទៅលើសកម្មភាពប្រមូលសំណាក និងការស្នើសុំការបំភ្លឺអំពីករណីនេះ (សូមមើលចំណុចទី៣ ខាងក្រោម) ព្រមទាំងចម្លងលិខិតផ្លូវការនេះទៅខ័ណ្ឌរដ្ឋបាលជលផលពាក់ព័ន្ធ។

៣.១. ប្រសិនបើការរកឃើញវិជ្ជមានទាក់ទងនឹងសារធាតុគីមីដែលត្រូវបានអនុញ្ញាត (ជាមួយ MRL) នោះលិខិតផ្លូវការនឹងស្នើសុំឱ្យវារីវប្បករបញ្ជាក់ពីការប្រើឱសថវារីវិតស្វទាំងអស់នៅក្នុងកសិដ្ឋានយ៉ាងហោចណាស់ក្នុងអំឡុងពេលមួយខែមុនកាលបរិច្ឆេទនៃការប្រមូលសំណាក។ ថ្ងៃផុតកំណត់សម្រាប់ការឆ្លើយតបពីវារីវប្បករ គឺអតិបរមា៣ថ្ងៃ បន្ទាប់ពីទទួលបានលិខិតផ្លូវការ។

ប្រសិនបើ ការពន្យល់ពីវារីវប្បករសំដៅទៅលើការខ្វះខាតចំណេះដឹងអំពីប្រភព ឬកំហុសក្នុងការប្រើប្រាស់ ឬកត់ត្រាទុក ការហាមឃាត់ត្រូវរក្សាទុករហូតដល់រយៈពេល ២០ ថ្ងៃ ហើយ I-Team ត្រូវចាត់តាំងប្រមូសំណាកបន្ថែមមុននឹងចេញការហាមឃាត់។

៣.២. ប្រសិនបើ ការរកឃើញវិជ្ជមានទាក់ទងនឹងឱសថវារីសត្វ និងសារធាតុគីមីហាមឃាត់ និង/ឬថ្នាំសម្លាប់សត្វល្អិត នោះលិខិតផ្លូវការត្រូវស្នើសុំឱ្យម្ចាស់កសិដ្ឋានបញ្ឈប់ការប្រើប្រាស់សារធាតុគីមី និងពន្យល់ថាតើឱសថវារីសត្វ និងអ្នកផ្គត់ផ្គង់ណាមួយដែលត្រូវបានប្រើប្រាស់។ ថ្ងៃផុតកំណត់សម្រាប់ការឆ្លើយតបពីវារីវប្បករគឺអតិបរមា ៣ ថ្ងៃបន្ទាប់ពីទទួលបានលិខិតផ្លូវការ។ ដើម្បីឆ្លើយតបនឹងការឆ្លើយតបរបស់វារីវប្បករ ឬម្ចាស់កសិដ្ឋាន ប្រធាន NRMP-C ត្រូវផ្ញើលិខិតផ្លូវការជាលាយល័ក្ខអក្សរ ដើម្បីជូនដំណឹង ស្តីពីផលជលផលទាំងអស់នៅក្នុងកសិដ្ឋានត្រូវរក្សាទុក (មិនចេញអាជ្ញាប័ណ្ណដឹកជញ្ជូន) រហូតដល់ការយកសំណាកគំរូ និងការវិភាគបញ្ជាក់ថា កម្រិតទាបជាង RPAs ដែលបង្កើតឡើងដោយច្បាប់កម្ពុជា។ លិខិតផ្លូវការនេះក៏ត្រូវចម្លងជូនទៅខណ្ឌរដ្ឋបាលជលផលពាក់ព័ន្ធ។

៣.៣. ប្រសិនបើការរកឃើញវិជ្ជមានទាក់ទងនឹងកម្រិតសំណល់ថ្នាំសម្លាប់សត្វល្អិត លោហធាតុធ្ងន់ ឌីអុកស៊ីត ដូចជា PCBs ខាងលើ MRL នោះ លិខិតផ្លូវការនឹងស្នើសុំឱ្យវារីវប្បករដាក់របាយការណ៍អំពីប្រភពនៃការចម្លងរោគ និងសកម្មភាពដែលអាចកើតមាន ដើម្បីជៀសវាងផលប៉ះពាល់ និងការកើតឡើងម្តងទៀត។ នៃប្រភពបែបនេះ។ លិខិតនេះត្រូវជូនដំណឹងដល់វារីវប្បករថា គាត់អាចត្រូវការជំនួយពី DAD ដើម្បីបង្កើតផែនការប្រមូលផលត្រី អាស្រ័យលើការស៊ើបអង្កេតបន្ថែមអំពីកម្រិតនៃការចម្លងរោគនៅក្នុងតំបន់ផ្សេងៗនៃកសិដ្ឋាន និងទំហំត្រី។ ច្បាប់ចម្លងនៃលិខិតនោះត្រូវផ្ញើទៅប្រធានខណ្ឌជលផលពាក់ព័ន្ធ។

៤. ប្រធាន NRMP-T ត្រូវចាត់តាំងក្រុមអធិការកិច្ចចម្រុះ ដើម្បីធ្វើការស៊ើបអង្កេត និងប្រមូលសំណាកបន្ថែមទៀត អាស្រ័យលើការឆ្លើយតបរបស់វារីវប្បករ ឬម្ចាស់កសិដ្ឋានដូចបានរៀបរាប់ខាងលើ។ ការចាត់តាំងត្រូវសរសេរជាលាយលក្ខណ៍អក្សរ រួមទាំងវិសាលភាពនៃការស៊ើបអង្កេត និងប្រមូលសំណាកគំរូ និងច្បាប់ចម្លងនៃការទំនាក់ទំនងជាមួយវារីវប្បករ។ ក្រុមអធិការកិច្ចនឹងអនុវត្តតាមវិធានទី៤ ក្នុងការអនុវត្តការស៊ើបអង្កេត/ប្រមូលសំណាកគំរូ និងរាយការណ៍ទៅប្រធានក្រុម NRMP-T ដែលនឹងជូនដំណឹងដល់ NRMP-C។ ប្រសិនបើការប្រមូលយកសំណាកគំរូបន្តត្រូវបានសម្រេច ដំណើរប្រតិបត្តិត្រូវអនុវត្តតាមវិធានទី៣។

### ៥.៦ ការប្រមូលសំណាកដើម្បីអង្កេតតាមដាន និងវាយតម្លៃសារជាថ្មី

| | |
|---|---|
| **អ្វី?**<br>What? | ធ្វើការស៊ើបអង្កេតនៅនឹងកន្លែងដើម្បីកំណត់ពីមូលហេតុដើម និងផលប៉ះពាល់បន្ថែមទៀតនៃការរកឃើញវិជ្ជមាននៃសំណល់ និងដើម្បីសម្រេចចិត្តលើវិធានការបន្ថែមទៀតដែលត្រូវអនុវត្ត។ |
| **ហេតុអ្វី/គោលបំណង?**<br>Why/Objective | ផ្តល់ទិន្នន័យសម្រាប់ធ្វើការសម្រេចចិត្តលើសកម្មភាពដែលត្រូវអនុវត្ត។ |
| **នរណា?**<br>Who | I-Team និង S-Team (ផ្អែកតាមការចាត់តាំង) |
| **ពេលណា?**<br>When | ការតាមដានបន្ត ដើម្បីពិនិត្យលើលទ្ធផលនៃវិធានទី៤។ ត្រូវផ្តួចផ្តើមសកម្មភាពភ្លាមៗនៅពេលដែលកាលបរិច្ឆេទកំណត់សម្រាប់ការឆ្លើយតបរបស់កសិដ្ឋានយោងតាមវិធានទី៤ ចំណុច ៣ ដែលត្រូវបានអនុម័ត។ |
| **យ៉ាងដូចម្តេច?**<br>How | - រៀបចំនិងចុះធ្វើការស៊ើបអង្កេតផ្ទាល់ រួមទាំងការប្រមូលយកសំណាកគំរូបន្ថែម ប្រសិនបើចាំបាច់ និងពិចារណាព័ត៌មានដែលទទួលបានពីវារីវប្បករ តាមវិធានទី៤។<br>- ជាគោលការណ៍អនុវត្តតាមវិធានទី២ ប៉ុន្តែត្រូវបន្តផ្តោតលើការកំណត់អត្តសញ្ញាណមូលហេតុដើម និងការជះឥទ្ធិពលលើផលិតផលដែលពាក់ព័ន្ធបន្ថែមទៀត ក្នុងការកំណត់ភាពមិនអនុលោមដែលបានកំណត់ទាំងនៅក្នុងការវាយតម្លៃ (បទសំភាសន៍ និងការសង្កេត) និងក្នុងការប្រមូលយកសំណាកគំរូ។<br>- ផ្ញើររបាយការណ៍ស៊ើបអង្កេតជូនទៅប្រធាន NRMP-T។ |
| **ទម្រង់ដែលត្រូវប្រើ**<br>Form to use | សៀវភៅកត់ត្រា/ឯកសារស្តីពីការរកឃើញភាពមិនអនុលោម។<br>គំរូរបាយការណ៍ទម្រង់ទី ៤ (ឧបសម្ព័ន្ធ ៩)។ |

## វិធានទី៤៖ ការបន្តតាមដាននិងត្រួតពិនិត្យលើការរកឃើញនូវវិជ្ជមាននៃភាពមិនអនុលោម



## ៥.៧ ការរៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

| | |
|---|---|
| **អ្វី?**<br>What? | រៀបចំសេចក្តីសង្ខេបនៃសកម្មភាពដែលបានអនុវត្ត ប្រៀបធៀបទៅនឹងសកម្មភាពដែលបានគ្រោងទុក ដោយផ្តោតលើករណីនៃការរកឃើញភាពមិនអនុលោម។ |
| **ហេតុអ្វី/គោលបំណង?**<br>Why/Objective | ពិនិត្យផ្ទៀងផ្ទាត់ការអនុវត្តសកម្មភាពដែលបានគ្រោងទុក និងពិចារណាលទ្ធផលក្នុងការរៀបចំផែនការឆ្នាំបន្ទាប់។ |
| **នរណា?**<br>Who | NRMP-T សហការជាមួយ I-Team និង S-Team |
| **ពេលណា?**<br>When | ជារៀងរាល់ខែ ត្រីមាស ឆមាស និងចុងឆ្នាំ តាមប្រតិទិន |
| **យ៉ាងដូចម្តេច?**<br>How | ចងក្រងទិន្នន័យស្តីពីការប្រមូលសំណាកទាំងអស់ លទ្ធផលធ្វើតេស្ត និងទិន្នន័យទាំងអស់ពី IMS និងសៀវភៅកំណត់ហេតុ/ឯកសារស្តីពីភាពមិនអនុលោម ដែលបានរកឃើញតាមឆ្នាំនីមួយៗ។ បំពេញទម្រង់លទ្ធផល ក្នុង Excel sheet និងគំរូរបាយការណ៍ពាក់ព័ន្ធ។ |
| **ទម្រង់ដែលត្រូវប្រើ**<br>Form to use | ទម្រង់ Excel sheet results template,<br>គំរូរបាយការណ៍ (ឧបសម្ព័ន្ធ ៦) - របាយការណ៍ប្រចាំខែ និងត្រីមាស<br>គំរូរបាយការណ៍ (ឧបសម្ព័ន្ធ ៧) - របាយការណ៍ប្រចាំឆ្នាំ |

## ៥.៨ ការតាមដាននិងវាយតម្លៃប្រចាំឆ្នាំ

| | |
|---|---|
| **អ្វី?**<br>What? | វាយតម្លៃប្រសិនបើ លក្ខខណ្ឌនិងការអនុវត្ត អនុញ្ញាតឱ្យមានដំណើរការប្រកបដោយប្រសិទ្ធភាព សម្រាប់ NRMP ហើយប្រសិនបើ NRMP មានលក្ខណៈគ្រប់គ្រាន់ដើម្បីផ្ទៀងផ្ទាត់ប្រសិទ្ធភាពនៃការគ្រប់គ្រងសំណល់នៃឱសថវារីសត្វ សារធាតុគីមីក្នុងផលវារីវប្បកម្ម និងការបំពុលបរិស្ថាន។ |
| **ហេតុអ្វី/គោលបំណង?**<br>Why/Objective | ការបន្តកែលម្អការគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារសម្រាប់ផលពីវារីវប្បកម្ម។ |
| **នរណា?**<br>Who | NRMP-C ។ |
| **ពេលណា?**<br>When | នៅពេលដែលគិតថាចាំបាច់ ប៉ុន្តែយ៉ាងហោចណាស់នៅចុងឆ្នាំ នៅពេលដែលរបាយការណ៍ប្រចាំឆ្នាំត្រូវបានទទួល។ |
| **យ៉ាងដូចម្តេច?**<br>How | ដោយផ្អែកលើរបាយការណ៍ដែលទទួលបានពី NRMP-T ត្រូវវាយតម្លៃលើបញ្ហាដូចខាងក្រោម៖<br>- សម្រេចគោលដៅទាក់ទងនឹងចំនួនសំណាកគំរូ និងប៉ារ៉ាម៉ែត្រដែលត្រូវធ្វើតេស្ត |

| | |
|---|---|
